អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ប្រទេសអូស្ត្រាលីបញ្ជាក់អំពីការផ្តល់ជំនួយថវិកាបន្ថែមចំនួន ២លានដុល្លារអូស្ត្រាលី ដល់ អ.វ.ត.ក

រដ្ឋាភិបាលអូស្ត្រាលីបានបញ្ជាក់អំពីការផ្តល់ជំនួយថ្មីទៀតនូវថវិកាចំនួន ២លានដុល្លារអូស្ត្រាលី (ប្រមាណ ២,១ លានដុល្លារសហរដ្ឋអាមេរិក) ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។ ក្នុងជំនួយនេះ ថវិកាចំនួន ១លានដុល្លារអូស្ត្រាលី នឹងត្រូវផ្តល់ជូនទៅភាគីជាតិ ហើយថវិកា ១លានដុល្លារអូស្ត្រាលី ទៀត នឹងត្រូវផ្តល់ជូនភាគីអន្តរជាតិនៃ អ.វ.ត.ក។

នៅក្នុងលិខិតមួយផ្ញើជូនថ្នាក់ដឹកនាំនៃ អ.វ.ត.ក ឯកឧត្តមឯកអគ្គរដ្ឋទូត ផេននី រីឆាដ លើកឡើងថា “អូស្ត្រាលីមើលឃើញថា អ.វ.ត.ក បានបោះជំហានដ៏សំខាន់ក្នុងការបញ្ចប់និរទណ្ឌភាពនៃឧក្រិដ្ឋកម្មដ៏សាហាវដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ដោយសម្រេចបានយុត្តិធម៌មួយកម្រិតសម្រាប់ជនរងគ្រោះ និងបានចូលរួមចំណែកក្នុងការផ្សះផ្សាជាតិ”។

ជាការឆ្លើយតប ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក  បានថ្លែងថា “ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទឹកចិត្តសប្បុរសនិងការបន្តគាំទ្ររបស់រដ្ឋាភិបាលអូស្ត្រាលី។ ជំនួយនេះមានសារសំខាន់ជាទីបំផុត ដើម្បីធានាថា អ.វ.ត.ក អាចបញ្ចប់បេសកកម្មរបស់ខ្លួនដោយជោគជ័យក្នុងការនាំយកយុត្តិធម៌មកជូនប្រជាជនកម្ពុជានិងជនរងគ្រោះនៃរបបខ្មែរក្រហម។”

ប្រទេសអូស្ត្រាលីស្ថិតក្នុងចំណោមប្រទេសម្ចាស់ជំនួយធំៗ ដែលបានផ្តល់ការគាំទ្រចំពោះ អ.វ.ត.ក តាំងពីពេលចាប់ផ្តើមដំណើរការដំបូង។ បូករួមទាំងជំនួយលើកចុងក្រោយនេះផង ប្រទេសអូស្ត្រាលីបានផ្តល់ជំនួយដល់ អ.វ.ត.ក ជាថវិកាសរុបចំនួន ១៦,៧លានដុល្លារអូស្ត្រាលី។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទៈ +៨៥៥(0) ២៣ ៨១៤ លេខបន្តៈ ៦១៦៩
សារអេឡិកត្រូនិកៈ olsenl@un.org

**ឌឹម សុវណ្ណារ៉ុំ**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥(0)១២ ៤៨៨ ០៩៤
សារអេឡិចត្រូនិកៈ dim.sovannarom@eccc.gov.kh

**យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទៈ +៨៥៥(0) ២៣ ៨១៤ លេខបន្តៈ ៦១៣៩
សារអេឡិកត្រូនិកៈ maeday@un.org